002/19-09-2007-ECCC/TC
E1/228

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / 10 / 2013
ម៉ោង (Time/Heure): 14 : 05
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

ថ្ងៃ ពុធ ទី ១៦ ខែ តុលា ឆ្នាំ ២០១៣

**សវនាការលើអង្គសេចក្តី-សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល-ថ្ងៃ ២១៥**

រៀបចំដោយ៖ **ដាវ អានសាន** និង **Roger PHILLIPS**

| <u>កំណត់ហេតុអ្នកចូលរួម</u> |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សាខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ដាវ អានសាន, លោក លឹម ស៊ុយហុង, លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ ជំទាវ ជា លាង, លោក Nicholas KOUMJIAN, លោក សេង ប៊ុនឃាង, លោក William SMITH, លោក Dale LYSAK, លោក វេង ហ៊ត់, លោក Keith REYNOR, លោក Vincent DE WILDE D'ESTMAEL, លោក Tarik ABDULHAK |
| ជនជាប់ចោទ៖ លោក នួន ជា, លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN លោកស្រី Anta GUISSE |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជអង្គ, លោកស្រី Elisabeth SIMONNEAU- |

| |
|---|
| FORT, លោក សំ សុខគង់, លោក ឡៅ ជុនធី, លោកស្រី ស៊ិន សូវន, លោកស្រី Martine JACQUIN, លោកស្រី Beini YE, លោក ហុង គីមសួន, លោក Olivier BAHOUGNE, លោកស្រី Lyma NGUYEN, លោក វ៉ែន ពៅ, លោកស្រី ជេត វណ្ណលី, លោកស្រី ទី ស្រីណា, លោកស្រី Christine MARTINEAU |
| សាក្សី/ដើមបណ្ដឹង៖ គ្មាន |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី សួ សុធារី |
| ផ្សេងៗ៖ លោក Simon MEISENBERG, កញ្ញា Paola ROBOTTI |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ | ចាប់ផ្ដើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ១៧.០៥ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.២៥ | បញ្ចប់ម៉ោង៖ ១០.៤៥ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៥.១០ | បញ្ចប់ម៉ោង៖ ១៥.៣៥ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៥ ម៉ោង និង ៥៥ នាទី |

| **កិច្ចដំណើរការនីតិវិធីផ្សេងទៀត** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
| ការចាប់ផ្ដើមសវនាការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល | អង្គជំនុំជម្រះ | ០៩.០០ | ០៩.០៨ |
| សេចក្ដីសន្និដ្ឋានផ្ទាល់មាត់ថ្លែងដោយសហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | លោក ពេជ អង្គ<br>លោក ហុង គីមសួន<br>លោក សំ សុខគង់<br>លោកស្រី ទី ស្រីណា<br>លោកស្រី Christine M.<br>លោកស្រី Elisabeth S.-F. | ០៩.០៨<br>០៩.៣១<br>១០.៤៧<br>១១.២៧<br>១៣.៣២<br>១៤.១៦ | ០៩.៣១<br>១០.២៤<br>១១.២៧<br>១២.០៦<br>១៤.១៦<br>១៥.៥៤ |
| សេចក្ដីសន្និដ្ឋានទាមទារសំណងស្ដារដោយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | លោកស្រី Elisabeth S.-F.<br>លោក ពេជ អង្គ | ១៥.៥៤<br>១៦.១៥ | ១៦.១៤<br>១៧.០៥ |
| ការចាកចេញរបស់ជនជាប់ចោទ | លោក នួន ជា | ០៩.១៧ | ០៩.១៨ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការចាប់ផ្តើមសវនាការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល**

ប្រធានអង្គជំនុំជម្រះប្រកាសហេតុក្នុងការចាប់ផ្តើមសវនាការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ស្របតាមវិធាន ៩៤ នៃវិធានផ្ទៃក្នុង និងយោងតាមអនុស្សរណៈស្តីពី "កាលវិភាគដែលត្រូវបានកែប្រែសម្រាប់ការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល" របស់ អជសអ ចុះថ្ងៃទី ២២ សីហា ២០១៣ (ឯកសារ E295/4) និងរំលឹកពីប្រវត្តិនីតិវិធីពាក់ព័ន្ធមួយចំនួន រួមទាំងវិធានមួយចំនួនក្នុងការធ្វើសន្និដ្ឋានផ្ទាល់មាត់ដោយភាគី។ ភាគីមានរយៈពេលធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ដោយសង្ខេបតាមវេលាកំណត់ដូចតទៅ៖ សហមេធាវីនាំមុខ ១ ថ្ងៃ, សហព្រះរាជអាជ្ញា ៣ ថ្ងៃ, ក្រុមការពារក្តី នួន ជា ២ ថ្ងៃ និង ក្រុមការពារក្តី ខៀវ សំផន ២ ថ្ងៃ។

**សេចក្តីសន្និដ្ឋានផ្ទាល់មាត់ក្នុងការបិទការពិភាក្សាដេញដោល ដោយសហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

លោក ពេជ អង្គ, លោក ហុង គឹមសួន, លោក សំ សុខគង់, លោកស្រី ទី ស្រីណា, លោកស្រី Christine MARTINEAU និង លោកស្រី Elisabeth SIMONNEAU-FORT បានឡើងថ្លែងសេចក្តីសន្និដ្ឋានរបស់ខ្លួន ជាបន្តបន្ទាប់។

**ការចាកចេញរបស់ជនជាប់ចោទ**

ជនជាប់ចោទ នួន ជា ស្នើសុំចាកចេញពីសវនាការ ដោយមូលហេតុមានអាការៈវិលមុខខ្លាំង។ អង្គជំនុំជម្រះបង្គាប់ឲ្យមន្ត្រីអនុរក្សនាំខ្លួនជនជាប់ចោទ នួន ជា ទៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ដើម្បីបន្តតាមដានដំណើរការសវនាការ។

**សេចក្តីសន្និដ្ឋានតាមការសំណងស្តារដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីថ្លែងសេចក្តីសន្និដ្ឋានចុងក្រោយរបស់ខ្លួនអំពីសំណើសុំជាគម្រោងសំណងរដ្ឋប្បវេណីស្តារចំពោះព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ បានទទួលរង ទាំងផ្នែកផ្លូវចិត្ត ផ្លូវកាយ និងផ្លូវសម្ភារៈ។ សំណើគម្រោងទាំងអស់មានចំនួន ១៤។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| លេខ E3 | លេខ កសចស | ចំណងជើង | ចំណាត់ថ្នាក់ | ERN ខ្មែរ | ERN អង់គ្លេស | ERN បារាំង |
|---|---|---|---|---|---|---|
| គ្មាន | | | | | | |

| <u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u> |
|---|
| • អង្គជំនុំជម្រះសាលាដំបូងប្រកាសអំពីការបញ្ចប់ការធ្វើសេចក្ដីសន្និដ្ឋានក្នុងការបិទការពិភាក្សាដេញដោលរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ សហព្រះរាជអាជ្ញានឹងធ្វើសេចក្ដីសន្និដ្ឋានរបស់ខ្លួននៅថ្ងៃទី ១៧ តុលា ២០១៣ ចាប់ផ្ដើមពីម៉ោង ០៩.០០ ព្រឹក (១៧.០៦)។<br>• បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា ទៅបន្តតាមដានដំណើរការសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការវិញ (នៅម៉ោង ០៩.១៨)។<br>• បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួន នួន ជា មកបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ និង ខៀវ សំផន មកសាលសវនាការវិញឲ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣ (ម៉ោង ១៧.០៦)។ |

| <u>កាលវេលាសវនាការបន្ត</u> |
|---|
| សវនាការនឹងបន្តទៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣ ចាប់ផ្ដើមពីម៉ោង ៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ជាវ អានសេង** **Roger PHILLIPS**